ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

**តុលាការព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖២៧៥
ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៩

**សាលក្រម**

លេខ៖ ២១៨ "ច"
ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២០

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តត្បូងឃ្មុំ

បានបើកសវនាការជាសាធារណៈនិងប្រកាសសាលក្រមនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២០ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

## ដើម្បីជំនុំជម្រះលើជនជាប់ចោទ

១-ឈ្មោះ [redacted] ហ៊ិន ភេទ ស្រី អាយុ ៤០ ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៣ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឫស្សី ឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ហួត (រ) ម្ដាយឈ្មោះ [redacted] ហ៊ាង (រ) ប្ដីឈ្មោះ [redacted] ទ្រី មានកូន០៤ នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ "គ្មាន" ជានីតិជន (ឃុំខ្លួនថ្ងៃទី ៣១-០៥-២០១៩ ដោះលែងឲ្យនៅក្រៅឃុំ និងដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការថ្ងៃទី ១២-០៦-២០១៩)។

២-ឈ្មោះ [redacted] **ស្រីម៉ៅ** ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៧ មុខរបរ លក់ឆ្នោត ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឫស្សី ឃុំរការពប្រាំ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ[redacted] រ៉ា (រ) ម្ដាយឈ្មោះ[redacted]ថា (រ) ប្ដីឈ្មោះ[redacted] សុខនី មានកូន ០២ នាក់ ទោសពីមុន៖ "គ្មាន" ជានីតិជន (ឃុំខ្លួនថ្ងៃទី ៣១-០៥-២០១៩ ដោះលែងឲ្យនៅក្រៅឃុំ និងដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការថ្ងៃទី ១២-០៦-២០១៩)។

៣-ឈ្មោះ [redacted] ទ្រី ហៅ ទ្រី ភេទ ប្រុស អាយុ ៥៥ ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៨ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឫស្សី ឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ[redacted] គឹមចេង (ស) ម្ដាយឈ្មោះ[redacted]រ៉េឡ (ស) ប្រពន្ធឈ្មោះ [redacted] ហ៊ិន មានកូន ០៤ នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ "គ្មាន" ជានីតិជន (ឃុំខ្លួនថ្ងៃទី ៣១-០៥-២០១៩ ដោះលែងឲ្យនៅក្រៅឃុំ និងដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការថ្ងៃទី ១២-០៦-២០១៩)។



Scanned with CamScanner

៤-ឈ្មោះ [redacted] ស្រីធំ ភេទ ស្រី អាយុ ៤៤ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៤ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ស៊ិត (ស) ម្តាយឈ្មោះ [redacted] សាយ (រ) ប្តីឈ្មោះ [redacted] ប៊ុណ្ណា មានកូន ០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ជានីតិជន (ឃុំខ្លួនថ្ងៃទី ៣១-០៥-២០១៩ ដោះលែងឲ្យនៅក្រៅឃុំ និងដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការថ្ងៃទី ១២-០៦-២០១៩)។

៥-ឈ្មោះ [redacted] សំ ភេទ ស្រី អាយុ ៤០ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៥ មុខរបរ លក់ឆ្នោត ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ស្រី (រ) ម្តាយឈ្មោះញាក់ ផៃលន់ (រ) ប្តីឈ្មោះ [redacted] ភា មានកូន ០៣ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ " គ្មាន" ជានីតិជន (ឃុំខ្លួនថ្ងៃទី ៣១-០៥-២០១៩ ដោះលែងឲ្យនៅក្រៅឃុំ និងដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការថ្ងៃទី ១២-០៦-២០១៩)។

-មានមេធាវីការពារសិទ្ធិះលោក [redacted] ។

៦-ឈ្មោះ [redacted] ស៊ីវលី ភេទ ស្រី អាយុ ៣០ ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៥ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] គាង (រ) ម្តាយឈ្មោះ [redacted] គីមហ៊ាង (រ) ប្តីឈ្មោះ [redacted] ហៃ មានកូន ០៤ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ជានីតិជន (ក្រៅឃុំ ដោយដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) ។

-មានមេធាវីការពារសិទ្ធិះលោក [redacted] ។

៧-ឈ្មោះ [redacted] លីសួង ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតសង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តត្បូងឃ្មុំ (ក្រៅឃុំ)។

ជាប់ចោទពីបទះ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ កម្លាំងសមត្ថកិច្ចការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ដឹកនាំដោយតំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ បានចុះទៅបង្ក្រាបទីតាំងកត់ឆ្នោតជាច្រើនកន្លែងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០៥ នាក់ គឺឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] សំ ភេទ ស្រី អាយុ ៤០ឆ្នាំ, ឈ្មោះ [redacted] ស្រីធំ ភេទ ស្រី អាយុ ៤៤ឆ្នាំ, ឈ្មោះ [redacted] ទ្រី ភេទ ប្រុស អាយុ ៥៥ឆ្នាំ, និងឈ្មោះ [redacted] ហ៊ាន់ ភេទ ស្រី អាយុ ៤០ ឆ្នាំ និងបានដកហូតវត្ថុតាងមួយចំនួនរួមមាន សៀវភៅកត់ឆ្នោតកន្ទុយលេខចំនួន ០៥ ក្បាល, ក្រដាស់កត់ឆ្នោតកន្ទុយលេខចំនួន ៣៣ សន្លឹក, ការបោន ០២សន្លឹក, ប៊ិចចំនួន ២១ ដើម, ទឹកលុបចំនួន ០២ ដើម, កាបូបយួរចំនួន០៣, ទូរស័ព្ទដៃចំនួន ០៦ គ្រឿង, ប្រាក់រៀលចំនួន ៣.៣៨០.០០០ រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ២០០ ដុល្លារ។ តាមចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ [redacted] ហ៊ាន់ និងឈ្មោះ [redacted] ទ្រី បានបញ្ជាក់ថា ខ្លួនកត់ឆ្នោតកន្ទុយលេខក្នុងមួយថ្ងៃបានប្រាក់ចំនួនមួយទៅពីររៀល ហើយប្រាក់មួយចំនួនបានវេរទៅឲ្យឈ្មោះ [redacted] សួង ភេទ ស្រី កាន់ទូរស័ព្ទលេខ ០៩៦ ២២២២ ៦០៦ និងលេខ ០៧៦ ៥៣៥៧ ៧៧៧ និងម្នាក់ទៀតមិនស្គាល់ឈ្មោះដែលប្រើទូរស័ព្ទលេខ ០១២ ៦១៦៧៤។

-**បានឃើញ** របាយការណ៍លេខ៖ ១៦៣/១៩ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១១៨ អ.យ/ឃ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ៣៦៧ ព្រ.ទ១ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ៣៣៥/២០២០ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

## នាពេលសវនាការ

១-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩ ឈ្មោះ [redacted] **ហ៊ីន** ជាជនជាប់ចោទ បានឆ្លើយសារភាពថា៖ខ្លួនបានរកស៊ីលក់ឆ្នោតកន្ទុយលេខពិតមែន ដោយលក់នៅផ្ទះដោយខ្លួនឯងខ្លះ និងមានកូនកញ្ច្រែងដើរកត់តាមផ្ទះខ្លះ កូនកញ្ច្រែងចុងក្រោយមានចំនួនបីនាក់ទេ គឺឈ្មោះ [redacted] សំ, ឈ្មោះ [redacted] **ស្រីធំ** និងឈ្មោះ[redacted] **ស្រីម៉ៅ**។ ការលក់លេខឆ្នោតក្នុងមួយថ្ងៃទទួលបានប្រាក់ពីចំនួន ១លាន រៀល ទៅ ២ លាន រៀល បើមានគេចាក់លើសពីចំនួន ២ ម៉ឺនរៀល ខ្លួនហៅបន្តតាមឡាញ (Line) ទៅឲ្យមេឆ្នោតនៅស្ទួងឈ្មោះ [redacted] លី (Siv Ly) ដែលមានលេខទូរស័ព្ទ ០១២ ៦១៦ ១៧៤ និងលេខមួយទៀតមិនចាំ ចំណែកលុយតម្កល់ទុកនៅខ្លួន បើមានគេចាក់ត្រូវយកលុយតម្កល់នោះបើកឲ្យគេ បើលើសចំនួនលុយតម្កល់ប្រាប់មេឆ្នោតឲ្យផ្ញើលុយឲ្យ បើគ្មានគេចាក់ត្រូវទេ លុយតម្កល់លើសពីចំនួន ៥លានរៀល ខ្លួនវេរតាមវីង ឬទ្រូម៉ាន់នីឲ្យទៅមេឆ្នោត។ មេឆ្នោតនៅស្ទួងខ្លួនមិនដែលបានជួបមុខទេ ស្គាល់លេខទូរតាមរយៈក្អួយមេឆ្នោតនោះប្រាប់។ ក្រៅពីមេឆ្នោតនៅស្ទួងឈ្មោះ [redacted] **លី** ខ្លួនមានសាងបន្តទៅឲ្យមេឆ្នោតនៅខ្នាឈ្មោះ [redacted] **ស្ទួង** ភេទ ស្រី អាយុប្រហែល ៣០ ឆ្នាំ ជាងម្នាក់ទៀត ដោយលេខឆ្នោតផ្ញើតាម Line ឯលុតផ្ញើតាមវីង។ លេខទូរស័ព្ទរបស់ខ្លួនដែលប្រើប្រាស់គឺមានលេខ ០៧៦ ៥៣៩ ៧៧៧ និងលេខ ០៩៦ ២២២២ ៦០៦។

២-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩ ឈ្មោះ[redacted] **ស្រីម៉ៅ** ជាជនជាប់ចោទ បានឆ្លើយសារភាពថា៖ ខ្លួនបានធ្វើជាកូនកញ្ច្រែងដើរកត់លេខឆ្នោតឲ្យមេឆ្នោតឈ្មោះ [redacted] **ហ៊ីន** បានរយៈពេលប្រហែល ០២ ខែកន្លះលុយលក់បានក្នុងមួយថ្ងៃៗចំនួនប្រហែល ១០ ម៉ឺនរៀល ហើយក្នុងប្រាក់ ១ម៉ឺនរៀល មេឲ្យកំរ៉ៃ ១ពាន់រៀល។

៣-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩ ឈ្មោះ[redacted] **ស្រីធំ** ជាជនជាប់ចោទ បានឆ្លើយសារភាពថា៖ ខ្លួនធ្វើជាកូនកញ្ច្រែងកត់លេខឆ្នោតឲ្យមេឆ្នោតឈ្មោះ[redacted] **ហ៊ីន** តាំងពីឆ្នាំ ២០១៨ មក ដោយទទួលបានប្រាក់ក្នុងមួយថ្ងៃៗពី ១០ម៉ឺនរៀល ទៅ ៤០ម៉ឺនរៀល ហើយទទួលបានកំរ៉ៃពីមេឆ្នោតក្នុងចំនួន ១០ម៉ឺនរៀល ទទួលបានចំនួន ១ម៉ឺនរៀល ។

៤-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩ ឈ្មោះ[redacted] **សំ** ជាជនជាប់ចោទ បានឆ្លើយសារភាពថា៖ ខ្លួនបានធ្វើជាកូនកញ្ច្រែងកត់លេខឆ្នោតឲ្យមេឆ្នោតឈ្មោះ [redacted] ហ៊ីន បានរយៈពេលប្រហែល០៦ ខែ ហើយលុយលក់បានក្នុងមួយថ្ងៃៗចំនួនប្រហែល ១០ម៉ឺនរៀលទៅ៤០ម៉ឺនរៀល ហើយក្នុងប្រាក់ ១០ម៉ឺនរៀល មេឲ្យកំរ៉ៃ ១ ម៉ឺនរៀល ។

៥-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩ ឈ្មោះ [redacted] **ទ្រី** ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថា៖ ខ្លួនគ្រាន់តែធ្លាប់ជួយកត់ឆ្នោតឲ្យប្រពន្ធម្តងម្កាល មិនដឹងថាប្រពន្ធលក់ឆ្នោតកន្ទុយលេខបានចំនួនប៉ុន្មាន

ក្នុងមួយថ្ងៃៗនោះទេ ពីព្រោះខ្លួនជាប់រវល់ក្នុងការរកស៊ីលក់ដូរគ្រឿងសំណង់មិនសូវចាប់អារម្មណ៍ទេ ហើយមកន្ទុយលេខឈ្មោះ [redacted] **សួង** និងឈ្មោះ [redacted] **លី** ខ្លួនមិនដែលស្គាល់ទេ។

៦-តាមអំណានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៩ ឈ្មោះ [redacted] **ស៊ីវលី** ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថា៖ ខ្លួនប្រើប្រាស់លេខទូរស័ព្ទ ០១២ ៦១៦ ១៧៤ និងលេខ ០១១ ៧៦២ ៧២៣ ពិតមែន, ខ្លួនបានស្គាល់គ្នាជាមួយឈ្មោះ [redacted] **ហ៊ិន់** មានរយៈពេលប្រហែលមួយឆ្នាំហើយ តែមិនមានទំនាក់ទំនងក្នុងរឿងបោះលេខឆ្នោតមកឲ្យខ្លួនទេ ហើយខ្លួនក៏ពុំមែនជាមេឆ្នោតរបស់ឈ្មោះ [redacted] **ហ៊ិន់** ដូចចម្លើយរបស់ឈ្មោះ [redacted] **ហ៊ិន់** នោះដែរ, ឈ្មោះ [redacted] **ហ៊ិន់** ធ្លាប់ផ្ញើលេខឆ្នោតមកឲ្យខ្លួនដើម្បីចាក់ឲ្យពី ០៤ លេខ ទៅ ១០ លេខ មែន ពេលចាក់អស់ប្រាក់គ្រប់ចំនួន ៥០ ម៉ឺនរៀល ទើបគាត់ផ្ញើលុយតាមឡានមកខ្លួនយកទៅសងឲ្យទៅមេឆ្នោត ពីព្រោះខ្លួនប្រាប់ថាមេឆ្នោតទារលុយ។ ខ្លួនមិនដែលទទួលបានកំរៃពីការចាក់ឆ្នោតឲ្យឈ្មោះ [redacted] **ហ៊ិន់** នោះទេ។ ចំពោះមេឆ្នោតនៅស្លូង ដែលឈ្មោះ [redacted] **ហ៊ិន់** បាញ់លេខឲ្យខ្លួនចាក់ឲ្យនោះ ខ្លួនមិនស្គាល់ឈ្មោះទេ លេខទូរស័ព្ទក៏មិនស្គាល់ដែរ ពីព្រោះមេឆ្នោតនោះដើរលក់ចល័ត មិនមានតូបត្រឹមត្រូវទេ ខ្លួនគ្រាន់តែដឹងថា មេឆ្នោតនោះជាមនុស្សស្រីមានអាយុប្រហែល ៤០ ឆ្នាំ។

៧-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីពិភាក្សាដេញដោល និងពិនិត្យលើឯកសារភស្តុតាងក្នុងសំណុំរឿងឃើញថា៖ មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ហេតុដូច្នេះ តំណាងអយ្យការសម្រេចរក្សាបទចោទដែល បានចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១១៨ អ.យ/យ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២០ ទុកជាបានការដដែល និងស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

៨-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **ហ៊ិន់**, ឈ្មោះ [redacted] **ស្រីម៉ៅ**, ឈ្មោះ [redacted] **ស្រីធំ**,ឈ្មោះ [redacted] **សំ** និងឈ្មោះ [redacted] **ទ្រី** បានធ្វើសេចក្តីសន្និដ្ឋានការពារតាមរយៈលិខិតចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២០ ថា កូនក្តីខ្លួនទាំងប្រាំនាក់រៀនសូត្របានតិចតួច មិនសូវយល់ដឹងអំពីច្បាប់មានជីវភាពខ្សត់ខ្សោយ ទើបឈានទៅប្រកបមុខរបរបែបនេះដើម្បីជួយផ្គត់ផ្គង់ដោះស្រាយជីវភាពគ្រួសារប្រចាំថ្ងៃ។ ប៉ុន្តែក្រោយពេលសមត្ថកិច្ចឃាត់ខ្លួន ឃុំខ្លួនមួយរយៈរួចដោះលែងឲ្យនៅក្រៅឃុំ កូនក្តីខ្លួនទាំងអស់មានការភ្ញាក់រលឹកយល់ពីកំហុស ដោយបានសន្យាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ ដូច្នេះខ្លួនស្នើសុំដល់តុលាការមេត្តាពិចារណា និងសម្រេចផ្តន្ទាទោសកូនក្តីខ្លួនត្រឹមដាក់ព្យួរធម្មតាដោយសេចក្តីអនុគ្រោះ ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **ស៊ីវលី** បានធ្វើសេចក្តីសន្និដ្ឋានការពារតាមរយៈលិខិតចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២០ ថា៖ តាមអង្គហេតុគ្មានចំណុចណាមួយដែលបញ្ជាក់ថាកូនក្តីខ្លួនជាអ្នកប្រព្រឹត្តបទល្មើសដូចបទចោទប្រកាន់ទេ ពោលគឺគ្មានធាតុផ្សំនៃបទល្មើស ។ ចម្លើយរបស់ឈ្មោះ ម៉េង ហ៊ិន់ ថាលេខឆ្នោតដែលរូបគេកត់បានគឺហៅបន្តទៅឲ្យមេឆ្នោតនៅស្លូងឈ្មោះ **ស៊ីវលី** តាមរយៈប្រព័ន្ធឡាញ និងវេរលុយតាមទូរស័ព្ទដែលមិនបានជួបមុខគ្នា គឺគ្មានសំអាងណាមួយបញ្ជាក់ថាឈ្មោះ **ស៊ីវលី** ជាកូនក្តីខ្លួនដែលឈ្មោះ [redacted] **ស៊ីវលី** នោះទេ, ម្យ៉ាងគ្មានសាក្សីបំភ្លឺថា បានឃើញកូនក្តីខ្លួនជាមេឆ្នោត ឬជាអ្នកបើកកន្លែងលេងល្បែងស៊ីសងនៅស្លូងនោះទេ។ ចំណុចមួយទៀត រូបថតដែលបានយកចេញពីគណនីឈ្មោះ **ស៊ីវលី** ក្នុងប្រព័ន្ធឡាញពុំមែនជារូបរបស់កូនក្តីខ្លួនឈ្មោះ [redacted] **ស៊ីវលី** ទេ ដូចនេះអាចបញ្ជាក់បានថា ទាំងលេខ ទូរស័ព្ទប្រើប្រាស់សម្រាប់វេរលុយក្នុងប្រព័ន្ធ Line ក៏ដូចជារូបថតនៅគណនី Line មិនអាចបញ្ជាក់អត្តសញ្ញាណថាមេឆ្នោតនៅស្លូងមានឈ្មោះ **ស៊ីវលី** ជាកូនក្តីខ្លួនឈ្មោះ [redacted] **ស៊ីវលី** បានឡើយ។ សរុបមក គ្រាន់តែជាវិមតិសង្ស័យប៉ុណ្ណោះ គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើកូនក្តីខ្លួនទេ ដូច្នេះ ខ្លួនស្នើសុំដល់តុលាការសម្រេចឲ្យក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

-ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ហ៊ិន់**, ឈ្មោះ [redacted] **ស្រីម៉ៅ**, ឈ្មោះ [redacted] **ស្រីធំ**,ឈ្មោះ [redacted] **សំ**, ឈ្មោះ [redacted] **ទ្រី** និងឈ្មោះ [redacted] **ស៊ីវលី**,

-ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋាននិងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋាន និងការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង ០៦ រូប

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តត្បូងឃ្មុំ
## យល់ឃើញថា

១-តាមដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៣៦៧ ព្រ.ទ១ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] **ស្រីម៉ៅ**,ឈ្មោះ [redacted] **ស្រីធំ**, ឈ្មោះ [redacted] **សំ**, ឈ្មោះ [redacted] **ទ្រី**, ឈ្មោះ [redacted] **ស៊ីវលី** និងឈ្មោះ [redacted] **លីសួង** ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទៈ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

ក្រោយពេលពិភាក្សាដេញដោល និងពិនិត្យលើភស្តុតាងទាំងអស់ក្នុងសំណុំរឿង ឃើញថាៈ អង្គហេតុបទល្មើសដែលបានចោទប្រកាន់លើជនជាប់ចោទទាំង ០៧រូប បានកើតឡើងពិតប្រាកដមែន ហើយជនជាប់ចោទឈ្មោះ [redacted] **ហ៊ាន់**, ឈ្មោះ [redacted] **ស្រីម៉ៅ**, ឈ្មោះ [redacted] **ស្រីធំ**, ឈ្មោះ [redacted] **សំ**, ឈ្មោះ [redacted] **ទ្រី**, ឈ្មោះ [redacted] **ស៊ីវលី** និងឈ្មោះ [redacted] **លីសួង** គឺពិតជាចារីនៃអំពើល្មើសនេះពិតប្រាកដមែនដែរ។ ការយល់ឃើញបែបនេះ ដោយផ្អែកលើហេតុផលដូចខាងក្រោមៈ

១.១-តាមរបាយការណ៍លេខៈ ១៦៣/១៩ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ បានបញ្ជាក់នូវអង្គហេតុនៃបទល្មើស ដែលអាចជឿជាក់ និងយកជាការបានថាៈ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ វេលាម៉ោង ១៤ និង ៣០ នាទី ជំនាញការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ទទួលបានព័ត៌មានថា នៅចំណុចភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ មានករណីបើកល្បែងមេឆ្នោតចាក់កន្ទុយលេខ បន្ទាប់មកកម្លាំងយើងបានចុះទៅស៊ើបអង្កេត ស្រាវជ្រាវ ដោយបានការឯកភាពពីលោកស្នងការ និងបានការសម្របសម្រួលដឹកនាំពីតំណាងអយ្យការ នៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ។ ដល់ម៉ោង ១១ និង ០០ នាទីនាថ្ងៃដដែល កម្លាំងយើងបានចុះបង្ក្រាបឃាត់ខ្លួនឈ្មោះ [redacted] **ហ៊ាន់** ភេទ ស្រី អាយុ ៤០ឆ្នាំ, ឈ្មោះ [redacted] **លី** ភេទ ប្រុស អាយុ ៥៥ឆ្នាំ, ឈ្មោះ [redacted] **ស្រីម៉ៅ** ភេទ ស្រី អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] **ស្រីធំ** ភេទស្រី អាយុ ៤៨ឆ្នាំ និងឈ្មោះ [redacted] **សំ** ភេទ ស្រី អាយុ ៤០ ឆ្នាំ។ ជនទាំង ០៥នាក់ រស់នៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ នាពេលចុះបង្ក្រាបសមត្ថកិច្ចបានដកហូតបាននូវវត្ថុតាងមាន សៀវភៅកត់ឆ្នោតកន្ទុយលេខចំនួន ០៥ក្បាល, ក្រដាស់កត់ឆ្នោតកន្ទុយលេខចំនួន ៣៣ សន្លឹក, កាបោន ០២ សន្លឹក, ប៊ិចចំនួន ២១ ដើម, ទឹកលុបចំនួន ០២ដើម, កាបូបយួរចំនួន ០៣, ទូរស័ព្ទដៃចំនួន ០៦ គ្រឿង (ប្រើថាច់ ០៤ គ្រឿង, ចុចពិល ០២ គ្រឿង), ប្រាក់រៀលចំនួន ៣.៣៨០.០០០ រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ២០០ អាមេរិកដុល្លារ។

១.២-ចម្លើយសារភាពទទួលស្គាល់កំហុសរបស់ជនជាប់ចោទឈ្មោះ [redacted] **ហ៊ាន់**, ឈ្មោះ [redacted] **ស្រីម៉ៅ**, ឈ្មោះ [redacted] **ស្រីធំ**, ឈ្មោះ [redacted] **សំ** និងឈ្មោះ [redacted] **ទ្រី** មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍ខាងលើ ដែលអាចឲ្យតុលាការជឿជាក់ថា ពួកគេជាចារីនៃអំពើល្មើសដែលបានចោទប្រកាន់ពិតប្រាកដមែន។

១.៣-ទោះបីជនជាប់ចោទឈ្មោះ [redacted] **ស៊ីវលី** ឆ្លើយបដិសេធមិនទទួលស្គាល់ថាៈ រូបគេមិនមែនជាមេឆ្នោតរបស់ឈ្មោះ [redacted] **ហ៊ាន់** ក៏ពិតមែន តែចម្លើយបដិសេធនេះមិនគួរឲ្យជឿ និងយកជាការបានទេ ពីព្រោះគ្មានអ្វី

ជាសំអាងជាក់លាក់។ ផ្ទុយទៅវិញ ជនជាប់ចោទរូបនេះបានទទួលស្គាល់ថារូបគេពិតជាត្រូវបានឈ្មោះ [redacted] ហ៊ាន់ ផ្ញើលេខឆ្នោតដើម្បីចាក់ឲ្យមានពី ០៤ លេខ ទៅ ១០ លេខ ពិតមែន ពេលចាក់អស់ប្រាក់ចំនួន ៥០ ម៉ឺនរៀល ទើបផ្ញើប្រាក់តាមឡានមកឲ្យខ្លួនយកទៅសងមេឆ្នោត។ ដូច្នេះ បង្ហាញឲ្យឃើញថា ជនជាប់ចោទរូបនេះពិតជាបាន ចូលរួមក្នុងសកម្មភាពលេងល្បែងស៊ីសងជាមួយជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់ ពិតប្រាកដមែន។ ចំណុចមួយទៀត លេខទូរស័ព្ទរបស់ជនជាប់ចោទប្រើប្រាស់គឺដូចគ្នាទៅនឹងលេខទូរស័ព្ទរបស់មេឆ្នោតនៅស្ទួង ដែលមិនអាចបដិសេធបានឡើយ ។

១.៤-ថ្វីត្បិតគ្មានចម្លើយដោះសារពីជនជាប់ចោទឈ្មោះ [redacted] ស្ទួង ក៏ដោយ តែមានចម្លើយដាក់បន្ទុកគ្រប់គ្រាន់ពីជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់ ដែលបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] ស្ទួង ជាចារីនៃអំពើល្មើសពិតប្រាកដមែន ។

១.៥-វត្ថុតាងដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់ ភេទ ស្រី អាយុ ៤០ ឆ្នាំ, ឈ្មោះ [redacted] លី ភេទ ប្រុស អាយុ ៥៩ឆ្នាំ, ឈ្មោះ [redacted] ស្រីម៉ៅ ភេទ ស្រី អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] ស្រីធំ ភេទ ស្រី អាយុ ៤៤ ឆ្នាំ និងឈ្មោះ [redacted] សំ ភេទ ស្រី អាយុ ៤០ ឆ្នាំ រួមមាន សៀវភៅកត់ឆ្នោតកន្ទុយលេខចំនួន ០៥ ក្បាល, ក្រដាស់កត់ឆ្នោតកន្ទុយលេខចំនួន ៣៣សន្លឹក, ការបោន ០២សន្លឹក, ប៊ិចចំនួន ២១ដើម, ទឹកលុបចំនួន ០២ដើម, កាបូបយួរចំនួន ០៣, ទូរស័ព្ទដៃចំនួន ០៦ គ្រឿង (ប្រើថាច់០៤គ្រឿង,ចុចពិល០២គ្រឿង) ,ប្រាក់រៀលចំនួន ៣.៣៨០.០០០ រៀល និងប្រាក់ដុល្លារអាមេរិកចំនួន២០០ដុល្លារ ។ វត្ថុតាងទាំងនេះ មានភាពស៊ីសង្វាក់ច្បាស់លាស់ទៅនឹងអង្គហេតុបទល្មើស ដែលអាចកំណត់បានថាជាផ្នែកមួយនៃធាតុសម្ភារៈ ចំពោះអំពើល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត។

សរុបមក អំពើរបស់ជនជាប់ចោទទាំង ០៧ រូបខាងលើ ដែលបានបើកកន្លែងលេល្បែងកត់ឆ្នោតកន្ទុយលេខ ដែលច្បាប់ហាមឃាត់ នេះជាបទល្មើស **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។ ដូច្នេះ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] ស្រីម៉ៅ,ឈ្មោះ [redacted] ស្រីធំ,ឈ្មោះ [redacted] សំ, ឈ្មោះ [redacted] ទ្រី, ឈ្មោះ [redacted] ស៊ីវលី និងឈ្មោះ [redacted] លីស្ទួង ពីបទ៖ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំកោពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។

២-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីពិភាក្សាដេញដោល ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] ស្រីម៉ៅ, ឈ្មោះ [redacted] ស្រីធំ, ឈ្មោះ [redacted] សំ, ឈ្មោះ [redacted] ទ្រី ឈ្មោះ [redacted] ស៊ីវលី និងឈ្មោះ [redacted] លីស្ទួង ហេតុដូច្នេះ តំណាងអយ្យការសម្រេចរក្សាបទចោទដែលបានចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១១៨ អ.យ/យ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំទុកជាបានការដដែល និងស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនចាប់ចោទទៅតាមច្បាប់។

ការប្តឹងសុំរបស់តំណាងអយ្យការ មានលក្ខណៈសមស្របទៅតាមសកម្មភាពប្រព្រឹត្ត និងអង្គហេតុនៃបទល្មើស ដូច្នេះ តុលាការនឹងសម្រេចតាមការប្តឹងសុំនេះ។

៣-សេចក្តីសន្និដ្ឋាន និងការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] ស្រីម៉ៅ, ឈ្មោះ [redacted] ស្រីធំ,ឈ្មោះ [redacted] សំ និងឈ្មោះ [redacted] ទ្រី ដែលបានស្នើសុំដល់តុលាការឲ្យពិចារណាលើស្ថានសម្រាល និងផ្តន្ទាទោសលើកូនក្តីខ្លួនដោយព្យួរទោស គឺមានលក្ខណៈសមហេតុសមផល ដែលអាចឲ្យតុលាការទទួលយកពិចារណា និង



Scanned with CamScanner

សម្រេចតាមការស្នើសុំបាន ដោយហេតុថា ជនជាប់ចោទភាគច្រើនជាស្ត្រី ភេទ ទើបប្រព្រឹត្តបទល្មើសជាលើកទីមួយ ហើយអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺដើម្បីដោះស្រាយជីវភាពគ្រួសារ ហើយសាមីខ្លួនមានការភ្ញាករលឹកបានឆ្លើយសារភាពមិនបង្កការលំបាកដល់សមត្ថកិច្ចទេ។ ម្យ៉ាងទៀត លក្ខខណ្ឌនៃការព្យួរទោសធម្មតាតាមមាត្រា ១០៤ មាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ក៏មានគ្រប់គ្រាន់សម្រាប់ជនជាប់ចោទទាំង៥ នាក់ ដូច្នេះ តុលាការនឹងសម្រេចព្យួរទោសទាំងមូលសម្រាប់ជនជាប់ចោទទាំង ០៥ នាក់។

៤-ចំពោះសេចក្ដីសន្និដ្ឋាន និងការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **ស៊ីវលី** ដែលស្នើសុំដល់តុលាការសម្រេចឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់ តុលាការមិនអាចសម្រេចតាមការស្នើសុំបានទេ ដោយហេតុថាភស្តុតាងបន្ទុកលើជនជាប់ចោទត្រូវបានរកឃើញ និងបញ្ជាក់ពីខាងលើរួចហើយ តុលាការនឹងសម្រេចផ្ដន្ទាទោសឲ្យ សមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជនជាប់ចោទ។ ដោយហេតុថា ជនជាប់ចោទជាស្ត្រី ភេទ ទើបប្រព្រឹត្តបទល្មើសជាលើកទីមួយ ហើយអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺដើម្បីដោះស្រាយជីវភាពគ្រួសារ។ ម្យ៉ាងទៀត លក្ខខណ្ឌនៃការព្យួរទោសធម្មតាតាមមាត្រា ១០៤ មាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ក៏មានគ្រប់គ្រាន់សម្រាប់ជនជាប់ចោទ ដូច្នេះ តុលាការនឹងសម្រេចព្យួរទោសទាំងមូលសម្រាប់ជនជាប់ចោទរូបនេះ ។

៥-ជនជាប់ចោទឈ្មោះ [redacted]សួង មិនព្រមចូលបង្ហាញខ្លួននៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយទៀតផង ជនជាប់ចោទរូបនេះមានសាវតារជាតិគ្រប់គ្រាន់ គប្បីចេញដីកាបង្គាប់ឲ្យចាប់-ឃុំខ្លួន យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-តាមកំណត់ដកហូតវត្ថុតាង ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ និងកំណត់ហេតុទទួលវត្ថុតាងលេខ ១០៧ អ.យ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ វត្ថុតាងដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទបញ្ជូនមកដល់តុលាការរួមមាន៖ សៀវភៅកត់ឆ្នោតកន្ទុយលេខចំនួន០៥ក្បាល , ក្រដាស់កត់ឆ្នោតកន្ទុយលេខចំនួន ៣៣សន្លឹក, ការបោន ០២សន្លឹក, ប៊ិចចំនួន ២១ដើម, ទឹកលុបចំនួន ០២ដើម, កាបូយួរចំនួន០៣, ទូរស័ព្ទដៃចំនួន ០៦ គ្រឿង (ប្រើចាច់០៤គ្រឿង, ចុចពិល០២គ្រឿង), ប្រាក់រៀលចំនួន ៣.៣៨០.០០០ រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ២០០ ដុល្លារអាមេរិក។

វត្ថុតាងខាងលើ គឺជាកម្មវត្ថុ និងជាមធ្យោបាយនៃបទល្មើស ដូច្នេះ តុលាការនឹងសម្រេចរឹបអូសអនុលោមតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៧-រឿងក្ដីនេះតុលាការបានសម្រេចលើអង្គសេចក្ដីហើយ ដូច្នេះ កាតព្វកិច្ចដែលចៅក្រមស៊ើបសួរដាក់ចំពោះជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] ស្រីម៉ៅ,ឈ្មោះ [redacted] ស្រីធំ,ឈ្មោះ [redacted] សំ និងឈ្មោះ [redacted] ទ្រី តាមដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក៏ត្រូវបញ្ចប់ដែរ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់ និងឈ្មោះ [redacted] ទ្រី បានដាក់ប្រាក់តម្កល់ម្នាក់ចំនួនចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល នៅសាលាដំបូងខេត្តត្បូងឃ្មុំ ដូច្នេះ តុលាការនឹងសម្រេចបង្វិលប្រាក់នេះទៅឲ្យជនជាប់ចោទទាំងពីរនាក់នេះវិញ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី

១-ផ្ដន្ទាទោសលើឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ [redacted] ស្រីម៉ៅ, ឈ្មោះ [redacted]ស្រីធំ, ឈ្មោះ [redacted] សំ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ស៊ីវលី ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទ៖ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិក្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង។



Scanned with CamScanner

២-ផ្តន្ទាទោសលើឈ្មោះ[redacted]សួង ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ពីបទ៖ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។

៣-ចេញដីកាបង្គាប់ឲ្យចាប់-ឃុំខ្លួនលើឈ្មោះ[redacted]សួង ដើម្បីយកអនុវត្តទោសតាមច្បាប់ ។

៤-រឹបអូសវត្ថុតាងរួមមាន៖ សៀវភៅកត់ឆ្នោតកន្ទុយលេខចំនួន ០៥ ក្បាល, ក្រដាស់កត់ឆ្នោតកន្ទុយលេខចំនួន ៣៣សន្លឹក, កាបោន ០២សន្លឹក, ប៊ិចចំនួន ២១ដើម, ទឹកលុបចំនួន ០២ដើម, កាបូបយួរ ចំនួន ០៣, ទូរស័ព្ទដៃចំនួន ០៦ គ្រឿង (ប្រើថាច់ ០៤ គ្រឿង, ចុចពិល ០២ គ្រឿង), ប្រាក់រៀលចំនួន ៣.៣៨០.០០០ រៀល និងប្រាក់ដុល្លារអាមេរិកចំនួន ២០០ ដុល្លារ។

៥-បង្វិលប្រាក់តម្កល់ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ទៅម្ចាស់ដើមឈ្មោះ[redacted] ហ៊ាន់ និង ៥.០០០.០០០ (ប្រាំលាន) រៀល ទៅឱ្យម្ចាស់ដើមឈ្មោះ[redacted]ទ្រី វិញ ។

សាលក្រមនេះកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ាន់, ឈ្មោះ[redacted]ស្រីម៉ៅ, ឈ្មោះ [redacted] ស្រីធំ, ឈ្មោះ [redacted] សំ, ឈ្មោះ[redacted]ទ្រី, ឈ្មោះ [redacted] ស៊ីវលី និងឈ្មោះ[redacted]សួង។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា៖[redacted]** **ហត្ថលេខា និងត្រា៖[redacted]**

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ ព្រហស្បតិ៍ ០១ រោច ខែ ពិសាខ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៣

ខេត្តត្បូងឃ្មុំ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២០

**បានឃើញ** **ក្រឡាបញ្ជី**

**ចៅក្រមជំនុំជម្រះ**

[redacted] [redacted]



Scanned with CamScanner